ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

# របាយការណ៍កិច្ចប្រជុំ
# ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី៣

**១. ថ្ងៃ ខែ ឆ្នាំ៖** ថ្ងៃសុក្រ ៤កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ត្រូវថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៣

**២. ទីកន្លែង៖** នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធអនឡាយ(Zoom)

**៣. ប្រធាន និងសមាសភាពចូលរួម ៖**

៣.១ ប្រធានអង្គប្រជុំ **ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

៣.២ សមាសភាពចូលរួមមាន សមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត និងអង្គការពាក់ព័ន្ធ ដែលចូលរួមផ្ទាល់ចំនួន៣១រូប និងតាមប្រព័ន្ធអនឡាយចំនួន៤៨រូប សរុបចំនួន៧៩រូប។

**៤. របៀបវារៈ៖**

៤.១- មតិស្វាគមន៍ និងគោលបំណងនៃកិច្ចប្រជុំដោយ **ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស។

៤.២- បទបង្ហាញស្តីពីគោលការណ៍ នីតិវិធី និងការអនុវត្តថវិកា គណៈកម្មធិការប្រយុទ្ធនឹងជំងឺអេដស៍ មេរោគអេដស៍ នៅរាជធានី និងខេត្ត

- កិច្ចប្រជុំផ្សព្វផ្សាយប្រកាសស្តីពីវិធានការ និងនីតិវិធីចំណាយ សម្រាប់វគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និងសន្និសិទ សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសលេខ៥៥៩ សហវ.អហក ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០២២ ស្តីពីវិធាន និងនីតិវិធីចំណាយប្រាក់បេសកកម្មក្នុង និងក្រៅប្រទេស សម្រាប់ថ្នាក់រដ្ឋបាលថ្នាក់ក្រោមជាតិ

៤.៣- មតិបូកសរុប និងបិទកម្មវិធីដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

## ៥. ដំណើរការសកម្មភាព៖

ជាកិច្ចចាប់ផ្ដើម **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស បានទទួលការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី៣ ឆ្នាំ២០២៣ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ដំណើរការនៃកិច្ចប្រជុំមាន៖

**៥.១ ឯកឧត្តមបណ្ឌិត** អគ្គលេខាធិការ បានមានប្រសាសន៍ជូនអង្គប្រជុំឱ្យបានជ្រាបថា កិច្ចប្រជុំថ្ងៃនេះផ្ដោតសំខាន់លើគោលការណ៍ នីតិវិធី និងការអនុវត្តថវិកា គណៈកម្មធិការប្រយុទ្ធនឹងជំងឺអេដស៍ នៅរាជធានីខេត្ត ការចំណាយសម្រាប់រៀបចំវគ្គបណ្ដុះបណ្ដាល កិច្ចប្រជុំ សិក្ខាសាលា និងសន្និសិទ ប្រាក់បេសកកម្មក្នុងស្រុក និងក្រៅប្រទេស សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ប្រធានបទនៃការពិភាក្សានេះ គឺក្នុងគោលបំណងពិនិត្យនូវលទ្ធផលដែលទទួលបានរួម និងឧបសគ្គនានាដែលអ្នកអនុវត្តផ្ទាល់បានជួបប្រទះ និងដាក់ចេញវិធានការអាទិភាព សម្រាប់ឆ្លើយតបឱ្យកាន់តែមានប្រសិទ្ធភាពឆ្ពោះទៅសម្រេចគោលដៅ៩៥ទី១ ដែលពេលនេះ ប្រទេសកម្ពុជាទើបសម្រេចបាន។

៥.២ តាមការខិតខំប្រឹងប្រែងពីអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** រួមជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានកំណត់យករដ្ឋបាលរាជធានី ខេត្តជាជំហានៗ ដើម្បីគ្រោង និងអនុវត្តថវិកាលើផែនការសកម្មភាពឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដោយកំណត់ដូចខាងក្រោម៖

- ចាប់ពីឆ្នាំ២០២២ (៨០លានរៀល/ឆ្នាំ)មាន ៤ រាជធានី/ខេត្ត រួមមាន៖ រាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបង
- ចាប់ពីឆ្នាំ២០២៣ (៦០លានរៀល/ឆ្នាំ) ចំនួន ១១ ខេត្ត រួមមាន៖ ខេត្តកណ្ដាល តាកែវ ព្រៃវែង ពោធិ៍សាត់ កំពង់ស្ពឺ ព្រះសីហនុ ត្បូងឃ្មុំ កំពង់ឆ្នាំង ប៉ៃលិន កំពង់ធំ និងកំពង់ចាម
- ចាប់ពីឆ្នាំ២០២៤ (៤០លានរៀល) មាន ១០ ខេត្ត រួមមាន៖ ខេត្តក្រចេះ មណ្ឌលគិរី ព្រះវិហារ កោះកុង ស្វាយរៀង ស្ទឹងត្រែង រតនគិរី កែប ឧត្តរមានជ័យ និងកំពត

**លទ្ធផលកិច្ចប្រជុំ**

- ការរៀបចំគម្រោង និងអនុវត្តថវិកា ៖

- ○ គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត ដែលមានអភិបាល ឬអភិបាលរង ខេត្ត ជាប្រធាន និងមាននាយកទីចាត់ការហិរញ្ញវត្ថុ ជាសេនាធិការ ត្រូវលើកសំណើរៀបចំគម្រោងចំណាយថវិកាតាមផែនការសកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍ ដោយអនុលោមតាមចំណាត់ថ្នាក់សេដ្ឋកិច្ច និងចំណាត់ថ្នាក់កម្មវិធីនៃមាតិកាថវិកា។
- ○ រដ្ឋបាលជាអាណាប័កបោះផ្សាយអាណត្តិទូទាត់ថវិកា ស្របតាមនីតិវិធីហិរញ្ញវត្ថុ ដោយមានទីចាត់ការហិរញ្ញវត្ថុរាជធានី ខេត្ត ជាអ្នកប្រមូលលិខិតឯកសារយុត្តិការ និងសក្ខីបត្រចំណាយ។

- នីតិវិធីអនុវត្តចំណាយ អាចប្រើប្រាស់នូវ នីតិវិធីទូទាត់ត្រង់ និងនីតិវិធីបើកផ្តល់សាច់ប្រាក់មុន។
- កែលម្អនូវបញ្ហាប្រឈមដែលមានកន្លងមក។
- ផ្សព្វផ្សាយនូវប្រកាសលខ ៥៥៩ សហវ.អហក ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០២២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីវិធាន និងនីតិវិធីចំណាយប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយក្នុងនោះបានបង្ហាញពីៈ ១)បទប្បញ្ញត្តិទូទៅ ២)សោហ៊ុយធ្វើដំណើរសម្រាប់បេសកកម្មនៅក្នុងប្រទេស ៣) វិធាន និងនីតិវិធីនៃអនុវត្តប្រាក់បេសកម្មនៅក្នុង និងក្រៅប្រទេស ៤) បទប្បញ្ញត្តិសម្រាប់បេសកកម្មនៅតាមតំបន់ជាប់ព្រំដែន ៥)បទប្បញ្ញត្តិដោយឡែក ៦) ទោសប្បញ្ញតិ និង៧) អវសានប្បញ្ញត្តិ។ សូមបញ្ជាក់ថា ប្រកាសលេខ ៥៥៩ សហវ.អហក មិនមានវិសាលភាពអនុវត្តចំពោះ ទីប្រឹក្សា ឬជំនួយការដែលមានឋានៈបន្ថែមក្រៅពីប្រព័ន្ធនៃរចនាសម្ព័ន្ធថ្នាក់ក្រោមជាតិ មន្ត្រីភូមិ ជំនួយការរដ្ឋបាលឃុំ សង្កាត់ និងមន្ត្រីជាប់កិច្ចសន្យាដែលមិនមានការទទួលស្គាល់ជាផ្លូវការដោយក្រសួងមុខងារសាធារណៈទេ។
- ផ្សព្វផ្សាយប្រកាសលេខ ៥៥៨ សហវ.ប្រក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីវិធាន និងនីតិវិធីចំណាយ សម្រាប់ការរៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំសិក្ខាសាលា និងសន្និសីទ សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ។ ក្នុងប្រកាសនេះ បានកំណត់នូវវិធាន និងនីតិវិធីចំណាយ ក្នុងក្របខ័ណ្ឌនៃឥណទានថវិកា អនុគណនី ៦១០៤១ (សោហ៊ុយសម្រាប់បណ្តុះបណ្តាលក្នុង និងក្រៅប្រទេស) និងអនុគណនី ៦១១០៣(ប្រជុំ សិក្ខាសាលា និងសន្និសីទ)។

នាឱកាសនោះតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសំណូមពរថ្នាក់ក្រោមជាតិនៅឆ្នាំ២០២៤ ត្រូវសម្រួចនូវផែនការសកម្មភាពទៅតាមតម្រូវការជាក់ស្តែងទៅតាមខេត្ត ក្រុង នីមួយៗរបស់ខ្លួន ដើម្បីងាយស្រួលក្នុងការអនុវត្ត (កន្លងមកផែនការសកម្មភាពបានធ្វើជាក្របខ័ណ្ឌរួម) និងការទូទាត់ថវិកាត្រូវរៀបចំឯកសារទុកដើម្បីងាយស្រួលក្នុការត្រួតពិនិត្យពីអាជ្ញាធរសាវណកម្ម និង អធិការកិច្ច។

ជាបន្ត **ឯកឧត្តមបណ្ឌិត** អគ្គលេខាធិការប្រធានអង្គប្រជុំបានបញ្ជាក់ថា នឹងទទួលយកនៅសំណើនៅក្នុងកិច្ចប្រជុំដែលបានលើកឡើង ព្រមទាំងស្នើសុំតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើបទបង្ហាញនៅក្នុង

កិច្ចប្រជុំប្រចាំត្រីមាសស្តីពីការពិនិត្យមើលវឌ្ឍនភាពនៃការអនុវត្តគម្រោងទីក្រុងពន្លឿនការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍នៅខេត្តសៀមរាបថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣ និងកិច្ចប្រជុំពេញអង្គ។

ចុងបញ្ចប់ **ឯកឧត្តមបណ្ឌិត** ប្រធានអង្គប្រជុំក៏បានបន្ថែមថា ការងារប្រយុទ្ធនឹងមេរោគអេដស៍ នៅមានរយៈពេលយូរទៅមុខទៀត ដែលតម្រូវឱ្យយើងបន្តធ្វើការរួមគ្នា រវាងអ្នកធ្វើគោលនយោបាយ និងយុទ្ធសាស្ត្រ អ្នកផ្តល់សេវា និងអ្នករងផលប៉ះពាល់។ ម្យ៉ាងទៀតត្រូវពង្រឹងភាពជាម្ចាស់ ចាំបាច់ត្រូវមានការផ្លាស់ប្តូរ ដើម្បីពិនិត្យលទ្ធភាពបង្កើនការផ្តល់ថវិកាជាតិ ដោយឡែកដល់ថ្នាក់ក្រោមជាតិដែលរួមមាន គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ រាជធានី ខេត្ត គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ស្រុក ខណ្ឌ និងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ឃុំ សង្កាត់ ដើម្បីបង្កើនបទអន្តរាគមន៍ឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ឱ្យចំលើការងារជាអាទិភាពពិសេសក្រុមប្រឈមមុខខ្ពស់ និងទីតាំងអាទិភាពដែលមានការចម្លងច្រើនដោយប្រើអន្តរាគមន៍ដែលមានប្រសិទ្ធភាពខ្ពស់ និងជាបណ្តើរៗជានាចីរភាព និងមានភាពធន់នៃប្រព័ន្ធជាតិឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍៕

ថ្ងៃអង្គារ ៧កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣

**បានពិនិត្យត្រឹមត្រូវ**

**អ្នកធ្វើរបាយការណ៍**

**ប្រធាននាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន**

**ប្រធានអង្គប្រជុំ**

**វេជ្ជ. ហួត សេរីវុធ្ន**

**ស៊ុំ ផល្លា**